CASDP

ព្រឹត្តិបត្រជោគជ័យ

# សមាសភាគអន្តរាគមន៍សម្រាប់ឆ្លើយតបសង្គ្រោះបន្ទាន់ផ្តោតលើវិបត្តិនៃជំងឺកូវីដ១៩

២០២៣




រៀបចំដោយ

ការិយាល័យសម្របសម្រួល
គម្រោងពិពិធកម្មកសិកម្មកម្ពុជា
**(CASDP/MAFF)**

077-563-377/012-449-693 https://casdp.maff.gov.kh/



# សាររបស់នាយកគម្រោង

ខ្ញុំសូមសំដែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារពិភពលោក (WB) សម្រាប់ការផ្តល់ហិរញ្ញប្បទានគាំទ្រសមាសភាគអន្តរាគមន៍ឆ្លើយតបសង្គ្រោះបន្ទាន់ (Contingency Emergency Response Component- CERC) ផ្តោតលើវិបត្តិនៃជំងឺកូវីដ១៩ នៅកម្ពុជាក្រោមគម្រោងពិពិធកម្មកសិកម្មកម្ពុជា (Cambodia Agricultural Sector Diversification Project (CASDP) ដែលផ្តួចផ្តើមឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការវិលត្រឡប់របស់កម្មករចំណាកស្រុក ក៏ដូចជាកម្មកររោងចក្រ ដែលបានបាត់បង់ការងារធ្វើដោយសារការរាតត្បាតនៃជំងឺកូវីដ១៩ បានបង្កភាពតានតឹងយ៉ាងខ្លាំងលើសហគមន៍ជនបទក្រីក្រជាច្រើន ហើយកិច្ចអន្តរាគមន៍របស់គម្រោងពិពិធកម្មកសិកម្មកម្ពុជាគាំទ្រសមាសភាគអន្តរាគមន៍ឆ្លើយតបសង្គ្រោះបន្ទាន់ផ្តោតលើវិបត្តិនៃជំងឺកូវីដ១៩ បានកាត់បន្ថយការលំបាកមួយចំនួនធំដែលគ្រួសារជនបទកំពុងជួបប្រទះ។ បទពិសោធន៍ក្នុងកិច្ចអន្តរាគមន៍របស់ CERC បានរួមចំណែកផ្តល់ចំណេះដឹងស្តីពី កម្មវិធីសង្គ្រោះបន្ទាន់ក្នុងគ្រាមានអាសន្ននៃផលប៉ះពាល់ពីជំងឺរាតត្បាតនៅកម្ពុជា។ CERC បានអនុញ្ញាតឱ្យយើងដឹងច្បាស់ពីការអនុវត្តល្អបំផុត ដើម្បីជម្រុញការស្តារឡើងវិញប្រកបដោយជោគជ័យ និងការអភិវឌ្ឍន៍ក្រោយវិបត្តិកូវីដ១៩ នៅកម្ពុជា។ ជាពិសេស CERC បានបង្ហាញយ៉ាងច្បាស់ថា ភាពជោគជ័យរបស់ CERC បានផ្តល់បទពិសោធន៍ផ្អែកលើភស្តុតាងជាក់ស្តែង និងបានទទួលស្គាល់ពីការអនុវត្តល្អបំផុតដែលគួរត្រូវបានរៀនសូត្របន្ត ដើម្បីយកទៅអនុវត្តប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតផ្សេងៗ និងកាត់បន្ថយផលប៉ះពាល់ផ្នែកសង្គម និងសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលខាងមុខ។

ខ្ញុំមានជំនឿថា ព្រឹត្តិបត្រស្តីពីភាពជោគជ័យក្នុងកិច្ចអន្តរាគមន៍របស់ CERC បានផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់រៀបចំកម្មវិធីគោលនយោបាយឆ្លើយតបសមស្របពាក់ព័ន្ធនឹងវិស័យកសិកម្ម ដែលអាចស្តារសេដ្ឋកិច្ចឡើងវិញកាន់តែរឹងមាំថែមទៀត ខណៈពេលដែលប្រទេសកម្ពុជា បានកំពុងធ្វើដំណើរនៅលើផ្លូវត្រឹមត្រូវឆ្ពោះទៅរកការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

**លោកបណ្ឌិត សរ ចិត្រា**
អគ្គលេខាធិការរង
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជា
នាយកគម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP)



# បថកថា

ការរាតត្បាតនៃជំងឺកូវីដ១៩ បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អាយុជីវិត និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា។ កម្មវិធីជាតិសង្គ្រោះបន្ទាន់ឆ្លើយតបទៅនឹងជំងឺរាតត្បាត និងសមត្ថភាពទប់ស្កាត់ជំងឺឆ្លងបានអនុវត្តទទួលបានជោគជ័យគួរឱ្យកត់សម្គាល់។ ដោយសាររាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការសុខមាលភាពសាធារណៈបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ ដើម្បីសម្រេចមហិច្ឆិតាកំណើន និងកាត់បន្ថយឥទ្ធិពលអវិជ្ជមានលើសេដ្ឋកិច្ចសង្គម។ ទោះជាយ៉ាងណាក៏ដោយ ជំងឺរាតត្បាតបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់កំណើនសេដ្ឋកិច្ច និងការងារ ហើយបានបង្អាក់ដំណើរការរីកចម្រើនរបស់ប្រទេសឆ្ពោះទៅការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ( SDGs)។

ព្រឹត្តិបត្រជោគជ័យនៃសមាសភាគអន្តរាគមន៍សម្រាប់ឆ្លើយតបសង្គ្រោះបន្ទាន់ (CERC) ផ្តោតលើវិបត្តិនៃជំងឺកូវីដ១៩ នៅកម្ពុជា នៅក្រោមគម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP) បានបង្ហាញថា ក្រុមងាយរងគ្រោះបំផុតជាអ្នកដែលទទួលរងវិបត្តិធ្ងន់ធ្ងរជាងគេ ហើយតម្រូវឱ្យមានការគាំទ្រមានភាពប្រាកដប្រជា។ CERC នៅកម្ពុជា ជាផ្នែកមួយនៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា ក្រោមហិរញ្ញប្បទានឥណទានពីធនាគារពិភពលោក និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( MAFF) ជាអ្នកអនុវត្តផ្ទាល់ ក្រោមកិច្ចសហការជាមួយក្រសួងពាក់ព័ន្ធរួមមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( MEF) ក្រសួងអភិវឌ្ឍន៍ជនបទ ( MRD) ក្រសួងធនធានទឹក និងឧតុនិយម ( MoWRAM) ។ CERC ត្រូវបានបង្កើតឡើងដោយផ្អែកលើរបាយការណ៍អង្កេតរបស់គម្រោង CASDP ដែលបានធ្វើឡើងក្នុងខែមិថុនា ឆ្នាំ២០២០ នៅក្នុងខេត្តគោលដៅចំនួន១៣។ CERC មានគោលបំណងលើកកម្ពស់ផលិតកម្មកសិកម្មរយៈពេលខ្លី ដើម្បីធានាថា គ្រួសារនៅជនបទមានលទ្ធភាពទទួលបានស្បៀងអាហារ និងស្វែងរកទីផ្សារផលិតផលដើម្បីរកប្រាក់ចំណូលសម្រាប់ស្តារជីវភាពគ្រួសារ។

ការរាតត្បាតនៃជំងឺកូវីដ១៩ជាបញ្ហាប្រឈមថ្មីដែលមិនធ្លាប់មានពីមុនមក ហើយឆ្លងកាត់បទពិសោធន៍នេះតម្រូវឱ្យកម្ពុជា ពង្រឹងសមត្ថភាពឱ្យកាន់តែប្រសើរឡើងថែមទៀតនាពេលអនាគត។ យើងកំពុងស្ថិតនៅក្នុងដំណាក់កាលដ៏សំខាន់មួយដែលត្រូវពិនិត្យឡើងវិញនូវភស្តុតាងចុងក្រោយ ហើយរៀបចំការគិតគូរពីរបៀបវារៈអភិវឌ្ឍន៍រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីស្តារឡើងវិញប្រកបដោយភាពធន់ ស្របតាមការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។ បទបពិសោធន៍ដែលទទួលបានពីភាពជោគជ័យរបស់ CERC នឹងត្រូវបានពិនិត្យយ៉ាងយកចិត្តទុកដាក់ដើម្បីកំណត់ពីសក្តានុពលដែលកើតចេញពីគំនិតផ្តួចផ្តើមរួមគ្នា បានជាគំនិតថ្មីក្នុងការអនុវត្តល្អបំផុតលើកម្មវិធីស្រដៀងគ្នានៅកន្លែងផ្សេងទៀតនៃប្រទេសកម្ពុជា។

ការិយាល័យធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា បានប្តេជ្ញាធ្វើការជាមួយកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា ដើម្បីគាំទ្រដល់ការកសាងប្រទេសកម្ពុជាឆ្ពោះទៅរកការស្តារឡើងវិញនូវសេដ្ឋកិច្ចដ៏រឹងមាំ មានភាពធន់ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ កិច្ចខិតខំប្រឹងប្រែងរួមរបស់យើងនាពេលនេះពិតជាមានការចាំបាច់ខ្លាំងជាងពេលណាៗទាំងអស់ ដើម្បីធានាថាគ្មាននរណាម្នាក់ត្រូវបានទុកចោលក្នុងការឆ្លើយតបបន្ទាន់ចំពោះវិបត្តិនេះ។

**លោកស្រី ចំរើន មុនិតា**
អ្នកឯកទេសជាន់ខ្ពស់អភិវឌ្ឍន៍ជនបទ និងជា
ប្រធានគម្រោងពិពិធកម្មកសិកម្មកម្ពុជា ធនាគារពិភពលោកប្រចាំកម្ពុជា

# សាវតារគម្រោង

ការរីករាលដាលនៃជំងឺកូវីដ១៩ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់វិស័យសំខាន់ៗ ដែលចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ចកម្ពុជា និងបានបន្តគំរាមកំហែងដល់វឌ្ឍនភាពនៃការអភិវឌ្ឍន៍ច្រើនឆ្នាំតទៅមុខទៀត។ ខណៈដែលកំណើនផលទុនសរុបក្នុងស្រុក (GDP) មានភាពរឹងមាំក្នុងរង្វង់៧,១% នៅឆ្នាំ២០១៩ហើយកំណើននេះបានធ្លាក់ចុះមកវិញក្នុងចន្លោះពី-១,0% និង-៣,១%នៅឆ្នាំ២០២០ ( ទិន្នន័យ ក.ហ.វ ឆ្នាំ២០២០ ) ។ វិស័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេមាន៖ វិស័យនាំចេញ វិស័យសំណង់ វិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ចរបស់កម្ពុជា ដែលត្រូវបានប៉ាន់ប្រមាណថា បានរួមចំណែកប្រហែល២០% ដល់កំណើនផលទុនសរុបក្នុងស្រុក។ វិស័យវាយនភ័ណ្ឌ និងការនាំចេញស្បែកជើងរបស់កម្ពុជាក៏បានធ្លាក់ចុះប្រមាណ-៥,៤% ក្នុងរយៈពេល៩ខែដំបូងនៃឆ្នាំ២០២០ ធៀបនឹងឆ្នាំ២០១៩ ដែលមានប្រមាណ១៩,១% ក្នុងរយៈពេលដូចគ្នា។ វិស័យដែលផ្តល់ការងារច្រើនជាងគេនៅកម្ពុជាមាន៖ វិស័យវាយនភ័ណ្ឌ១៧% វិស័យមិនមែនកសិកម្ម វិស័យដឹកជញ្ជូន និងបដិសណ្ឋារកិច្ច១១% និងសំណង់៤% ( ទិន្នន័យ ក.ហ.វ.២០២០ ) ។

សម្រាប់វិស័យកសិកម្មវិញ កម្ពុជាបាននាំចូលបន្លែ៣២% ត្រី២៥% និងសាច់ប្រហែល២០% ដើម្បីបំពេញតម្រូវការប្រើប្រាស់ក្នុងស្រុក។ ដូច្នេះ កម្ពុជាត្រូវមានវិធានការច្បាស់លាស់ក្នុងការបង្កើនផលិតកម្មស្បៀងក្នុងស្រុក សំដៅកាត់បន្ថយការពឹងផ្អែកលើទំនិញនាំចូលផលិតផលស្បៀងពីប្រទេសជិតខាង។ វិធានការនេះនឹងដោះស្រាយភាពអត់ការងារធ្វើនៅចំពោះមុខសម្រាប់ជនដែលបានបាត់បង់ការងារផង និងជនចំណាកស្រុកផង ដោយធានាថាគ្រួសារងាយរងគ្រោះមានអាហាររូបត្ថម្ភគ្រប់គ្រាន់។

កង្វះអាហាររូបត្ថម្ភនៅតែជាបញ្ហាប្រឈមក្នុងការអភិវឌ្ឍន៍មនុស្សនៅកម្ពុជា របបអាហារដែលយើងកំពុងទទួលទានមិនមានសារធាតុចិញ្ចឹមគ្រប់គ្រាន់។ គ្រួសារតែ២១% ប៉ុណ្ណោះដែលមានលទ្ធភាពទទួលបានរបបអាហាររូបត្ថម្ភមានជីវជាតិ ហើយអាហារភាគច្រើនដែលគ្រួសារកសិករក្រីក្រងាយរងគ្រោះបរិភោគជាអាហារមិនមានសុវត្ថិភាព។ ប្រការគួរឱ្យកត់សម្គាល់មួយទៀត គឺអត្រាកុមារម្នាក់ក្នុងចំណោមកុមារបីនាក់ ( ស្មើ៣២% ) ក្រោមអាយុ៥ ឆ្នាំនៅឆ្នាំ២០១៤ មានសភាពក្រិនមិនលូតលាស់ ( កម្ពស់មិនសមអាយុ ) និងមានរាងកាយកង្វះអាហារូបត្ថម្ភ (FAO.2014)។

ការរីករាលនៃជំងឺកូវីដ១៩ បានបន្ថែមបញ្ហាប្រឈមដល់ការរក្សាបានប្រព័ន្ធអាហាររូបត្ថម្ភដែលកំពុងមានបញ្ហាស្រាប់។ ត្រី សាច់ និងបន្លែ ជាផ្នែកមួយនៃការប្រើប្រាស់តាមទម្លាប់ ហើយប្រជាជនភាគច្រើនពឹងផ្អែកតែទៅលើអង្ករ និងបន្លែតែមួយមុខ ជារបបអាហារសំខាន់ដែលនាំឱ្យរបបអាហារមិនមានតុល្យភាព ខ្វះប្រូតេអ៊ីនគ្រប់គ្រាន់។ ការបិទខ្ទប់ក្នុងដំណាក់កាលរីករាលដាលនៃជំងឺកូវីដ១៩ បានធ្វើឱ្យប៉ះពាល់ដល់កសិកររាប់ពាន់នាក់បាត់បង់ប្រាក់ចំណូល និងអាហាររូបត្ថម្ភសម្រាប់សុខភាពគ្រួសារ។

បញ្ហាប្រឈមខាងលើតម្រូវឱ្យមានសកម្មភាពដោះស្រាយបន្ទាន់។ កិច្ចពិភាក្សាក្នុងក្របខណ្ឌភាពជាដៃគូរបស់ធនាគារពិភពលោក (Country Partnership Framework) សម្រាប់ប្រទេសកម្ពុជានៅឆ្នាំ២០១៩-២០២៣ ស្របគ្នាទៅនិង

កម្មវិធីប្រយុទ្ធប្រឆាំងនឹងការរាតត្បាតនៃជំងឺកូវីដ១៩របស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានលើកយកមកពិភាក្សា ដោយឆ្លុះបញ្ចាំងពីតម្រូវការបន្ទាន់ក្នុងការដោះស្រាយផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ១៩ ដល់វិស័យមិនមែនសុខាភិបាល។

រាជរដ្ឋាភិបាលកម្ពុជាបានស្នើដល់ធនាគារពិភពលោកជួយដោះស្រាយវិបត្តិកូវីដ១៩ និងជំរុញការស្តារសេដ្ឋកិច្ចនាពេលអនាគត។ ដូច្នេះហើយ CERC ត្រូវបានបង្កើតឡើង ដើម្បីបង្កើនផលិតភាពកសិកម្មដល់គ្រួសារងាយរងគ្រោះនៅជនបទ និងជនជាតិដើមភាគតិច ដោយបង្កលទ្ធភាពក្នុងការអភិវឌ្ឍខ្សែច្រវាក់តម្លៃកសិកម្មក្នុងស្រុក និងតំបន់គោលដៅមួយចំនួន ក៏ដូចជាគាំទ្រកសិករខ្នាតតូចក្នុងការកសាងសមត្ថភាពរកប្រាក់ចំណូល និងភាពធន់នឹងផលវិបាកនៃជំងឺកូវីដ១៩។ ថវិកា១០,២០០,០១ដុល្លារអាមេរិក ក្រោមហិរញ្ញប្បទានធនាគារពិភពលោក រួមទាំងថវិកាបដិភាគពីរាជរដ្ឋាភិបាល ត្រូវបានបញ្ចេញសម្រាប់គាំពារសន្តិសុខស្បៀង ដែលជាវិធានការសង្គ្រោះបន្ទាន់រយៈពេលខ្លី ដើម្បីបង្កើនភាពធន់របស់ប្រជាជនងាយរងគ្រោះនៅតាមគោលដៅនៅជនបទ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង លើកកម្ពស់ជីវភាព និងការបង្កើតការងារ។

CERC បានជ្រើសរើសគ្រួសារក្រីក្រមកពីរាជធានី-ខេត្តគោលដៅចំនួន១៣ នៃគម្រោង CASDP រួមមាន ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង បាត់ដំបង សៀមរាប ព្រះវិហារ ស្ទឹងត្រែង ក្រចេះ រតនគិរី មណ្ឌលគិរី ត្បូងឃ្មុំ កំពង់ចាម និងភ្នំពេញ។ ខេត្តគោលដៅទាំងនេះត្រូវបានជ្រើសរើសផ្អែកលើលក្ខណវិនិច្ឆ័យត្រឹមត្រូវ ស្របតាមលទ្ធផលរបាយការណ៍វាយតម្លៃពីតម្រូវការជាក់ស្តែងរបស់គ្រួសារកសិករ ឬក្រុមអ្នកផលិត គ្រួសារងាយរងគ្រោះ គ្រួសារខ្វះលទ្ធភាពមានដី ឬប្រភពទឹក និងធនធានចាំបាច់ផ្សេងទៀត ហើយដែលមានបំណងចូលរួមសកម្មភាពជាមួយផលិតកម្មបន្លែសុវត្ថិភាព ការចិញ្ចឹមមាន់ និងវារីវប្បកម្ម ( ត្រី និងកង្កែប ) ។ CERC បានរៀបចំចងក្រងផែនការផលិតកម្មលើកកម្ពស់ផលិតផលកសិកម្មរយៈពេលខ្លី ដើម្បីបំពេញសេចក្តីត្រូវការសម្រាប់ប្រើប្រាស់ក្នុងផ្ទះ និងផ្គត់ផ្គង់ទីផ្សារក្នុងស្រុក។ CERC បានធានានិរន្តរភាពហិរញ្ញវត្ថុដោយមិនចាំបាច់មានតម្រូវការដីច្រើន ងាយស្រួលដឹកជញ្ជូនធាតុចូលកសិកម្ម និងលទ្ធភាពទទួលបានសេវាគាំទ្រកសិកម្មរបស់កសិករ ដែលផ្តល់ដោយរដ្ឋាភិបាល ឬវិស័យឯកជន។



រូបភាព៖MAFF 2020

# សកម្មភាពអន្តរាគមន៍ និងលទ្ធផលសម្រេចបាន

## គម្រោងចិញ្ចឹមមាន់

CERC តាមរយៈអង្គការសកម្មភាពដើម្បីអភិវឌ្ឍន៍ (AFD) ដែលបានទទួលកិច្ចសន្យាចែកចាយធាតុចូលកសិកម្ម ជំនួយបច្ចេកទេសកសិកម្ម និងសម្ភារផ្សេងៗទៀតរួមមាន វ៉ាក់សាំង និងចំណីសត្វ។ គម្រោងបានដំឡើងទ្រុងមាន់ចំនួន២,៩២៩ទ្រុង ដល់កសិករខ្នាតតូចចំនួន៥,៨៥៨គ្រួសារ ដោយ២គ្រួសារទទួលបានទ្រុង១។

ជាមួយគ្នានេះដែរ ដើម្បីគាំទ្រដល់ការចិញ្ចឹមមាន់ ភ្នាក់ងារសុខភាពសត្វភូមិ (Village Animal Health Workers-VAHWs) ទទួលបានការបណ្តុះបណ្តាលបច្ចេកទេសបន្ថែមដើម្បីពង្រឹងសមត្ថភាព តាមដានការអនុវត្តនៅនឹងកន្លែងសំដៅគាំទ្រដល់ការចិញ្ចឹមមាន់របស់កសិករឱ្យទទួលបានផលល្អ។ មុនពេលចែកធាតុចូលកសិកម្ម គម្រោងបានបណ្តុះបណ្តាលគ្រូបង្គោល (ToT) ដែលជាភ្នាក់ងារសុខភាពសត្វ មានសមត្ថភាពណែនាំដល់គ្រួសារចិញ្ចឹមមាន់នៅក្នុងសហគមន៍ក្នុងរយៈពេលវែង។ វគ្គបណ្តុះបណ្តាលនេះ បានផ្តោតលើការរៀបចំផែនការ និងបទដ្ឋានបច្ចេកទេសធ្វើទ្រុងស្របតាមស្តង់ដារ ការចិញ្ចឹមមាន់ ឱ្យចំណី ថែទាំ ជ្រើសរើសពូជ និងការថែរក្សាបរិស្ថានផងដែរ។

គម្រោងបានធ្វើការជាមួយភ្នាក់ងារសុខភាពសត្វភូមិ (VAHWs) ដើម្បីឱ្យពួកគេមានសមត្ថភាពណែនាំ និងមានប្រសិទ្ធភាព តាមរយៈការតាមដាន និងបំពាក់បំប៉នជាប្រចាំសំដៅគាំទ្រដោយផ្ទាល់ដល់កសិករចិញ្ចឹមមាន់។ ក្រុមការងារក៏បានផ្តល់ការណែនាំបន្ថែមអំពីរបៀបថែទាំកូនមាន់ ណែនាំឱ្យពង្រឹងជីវសុវត្ថិភាព អនុវត្តវិធានអនាម័យ និងការព្យាបាលជំងឺមាន់។



កសិករ **៥,៨៥៨** ជាអ្នកទទួលផល

ភ្នាក់ងារសុខភាពសត្វភូមិ



ទ្រុងមាន់ **២,៩២៩** បានដំឡើងរួច

ចំណីមាន់ **២០,៩២៩** បានចែកជូនអ្នកទទួលផល

ផលិតផលមាន់យកសាច់ **២៧៧.៤១** តោន

# គម្រោងចិញ្ចឹមត្រី

ក្រុមហ៊ុន អប្សរា ទទួលបានកិច្ចសន្យាអនុវត្តគម្រោងចិញ្ចឹមត្រី និងកង្កែប។ គម្រោងបានផ្តល់ធុងប្លាស្ទីក កៅស៊ូតង់ ចំណីត្រី និងកង្កែប កូនត្រីអណ្តែង និងជំនួយបច្ចេកទេសសង់អាងចិញ្ចឹម និងសកម្មភាពតាមដានការអនុវត្តជាដើម។ កសិករអ្នកទទួលផលចំនួន២,១៣៩ គ្រួសារ ត្រូវបានជ្រើសរើសចេញពីសហគមន៍កសិកម្មទាំង១៣ ខេត្តក្រុងនៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា។ កសិករទាំងនោះជាជនរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩រួមមាន កម្មករបាត់បង់ការងារចំនួន១៣៥៣នាក់ ក្នុងនោះ៧៤៣នាក់ជាស្ត្រី។ កម្មករចំណាកស្រុកចំនួន២៦៩១៩នាក់ មានស្ត្រីចំនួន១១៣១៣នាក់ ប្រជាជនសរុបចំនួន៣០៧៨២៤នាក់ រួមមានស្ត្រី១១៦៨៣៧ នាក់ ត្រូវបានចាត់ថ្នាក់ជាប្រជាជនកាន់បណ្ណក្រីក្រ(ID.Poor)។

ធាតុចូលកសិកម្មដែលកសិករទទួលបានពី CERC រួមមាន ធុងប្លាស្ទីក/ជប ចំណី កូនត្រី និងជំនួយបច្ចេកទេស តង់ស្តុកទឹកភ្លៀង និងធុងប្លាស្ទិក សកម្មភាពដំឡើងអាងចិញ្ចឹម និងកម្មវិធីតាមដានការអនុវត្ត និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតក៏បានដាក់បញ្ចូលទៅក្នុងកម្មវិធីតាមដានការអនុវត្តផងដែរ។ ក្រៅពីនេះ គ្រួសារអ្នកទទួលផលពី CERC ចំនួន២,១៣៩ នៅតាមរាជធានី-ខេត្តគោលដៅទាំង១៣ បានទទួលកូនកង្កែបចំនួន១,៧២៣ក្បាល ចំណីចំនួន៤១០,៦៨៨ គីឡូ និងកូនកង្កែបចំនួន២,១៣៩,០០០ ក្បាល។

ក្រៅពីផ្តល់ធាតុចូលកសិកម្ម គម្រោងបានសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹម ការជ្រើសរើសទីតាំងស្របតាមលក្ខខណ្ឌជីវសាស្ត្រ ការទុកដាក់សម្ភារៈ និងការសង់អាងចិញ្ចឹមស្របតាមដង់ស៊ីតេសម្រាប់ចិញ្ចឹម របៀបដឹកជញ្ជូនកូនកង្កែប និងកូនត្រីអណ្តែង របៀបព្រលែងកូនត្រី ឬកង្កែប ចូលទៅក្នុងអាងចិញ្ចឹម ការគ្រប់គ្រងគុណភាពទឹក ឬប្រភពទឹក (ឧបករណ៍បិទបើកទឹកបញ្ចូលពីអណ្តូង ប្រឡាយ ស្រះ បឹង អូរ និងទន្លេ និងការបញ្ចេញទឹកកខ្វក់ពីអាងចិញ្ចឹម) ច្ចេកទេសចិញ្ចឹម និងឱ្យចំណី ការថែទាំ ការប្រមូលផល ការប្រើប្រាស់ខ្លួនឯង និងការផ្គត់ផ្គង់ទៅកាន់ទីផ្សារ។

ក្រុមការងារក្រុមហ៊ុនអប្សរា បានពន្យល់ផ្នែកបច្ចេកទេសតាមរយៈសៀវភៅណែនាំដល់កសិករ ឱ្យបានយល់ដឹងពីរបៀបចិញ្ចឹម និងថែទាំ។ សំខាន់ជាងនេះ បច្ចេកទេសចិញ្ចឹម ការឱ្យចំណី ការថែទាំ ការពិនិត្យ ឬសង្កេតជាប្រចាំក៏ត្រូវបានលើកយកមកអនុវត្តក្នុងពេលនោះដែរ។ តាមការអង្កេតជាទូទៅបានឱ្យដឹងថា អត្រារស់រានមានជីវិតរបស់ត្រីអណ្តែង និងកង្កែបអាចមានចន្លោះពី៨៥% ឡើងទៅ។ រីឯចំនួនស្លាប់វិញមានប្រមាណពី១០ ទៅ១៥% ក្នុង១វដ្តចិញ្ចឹម។

ជាមួយនឹងការផ្តល់ធាតុចូលកសិកម្ម និងសេវាប្រឹក្សាយោបល់វិញ CERC បានជួយឱ្យកសិករសម្រេចបានវឌ្ឍនភាពគួឱ្យកត់សមគាល់។ កសិករមួយចំនួនបានចែករំលែកបទពិសោធន៍ និងព័ត៌មានដោយអស់ពីចិត្តអំពីបច្ចេកទេសចិញ្ចឹមត្រី/កង្កែបជាមួយសមាជិកសហគមន៍របស់ពួកគេ ដើម្បីលើកទឹកចិត្តពួកគេឱ្យងាកមកចិញ្ចឹមកង្កែបដើម្បីប្រាក់ចំណូលគ្រួសារ។



គ្រួសារ **២,១៣៩** បានទទួលបានកូនត្រី និងកង្កែប

ចំណីត្រី និងកង្កែប **៤១០,៦៨៨** គីឡូត្រូវបានចែកចាយដល់កសិករអ្នកទទួលផល

កូនត្រីអណ្តែង **២,១៣៩,០០០** បានផ្តល់ជូនកសិករអ្នកទទួលផល



តង់ផ្លាស្ទីក (ត្រី និងកង្កែប) **១,៧២៣** បានផ្តល់ជូនកសិករអ្នកទទួលផល

អាងចិញ្ចឹមធ្វើពីតង់ផ្លាស្ទីក **៤១៦** ត្រូវបានចែកចាយដល់កសិករអ្នកទទួលផល

# គម្រោងបន្លែសុវត្ថិភាពក្នុងផ្ទះសំណាញ់

ក្រុមហ៊ុន ត្រូភីខេម (TropiCam) ជាក្រុមហ៊ុនទទួលបានសិទ្ធអនុវត្តគម្រោងដាំបន្លែសុវត្ថិភាពក្នុងផ្ទះសំណាញ់ តាមរយៈ CERC ដែលបានអនុវត្តរយៈពេល៦ខែ លើការងារផ្គត់ផ្គង់ធាតុចូលកសិកម្ម និងជំនួយបច្ចេកទេសបន្លែសុវត្ថិភាព។ គ្រួសារចំនួន៣,៦០០ ទទួលបានផ្ទះសំណាញ់ និង៣,៦៩៦ គ្រួសារ ជ្រើសរើសចេញពីគ្រួសារចំនួន៧,២៩៦ ទទួលបានសម្ភារកសិកម្មរួមមាន កូនបន្លែ ជីកសិកម្ម សម្ភារផ្សេងទៀត។

ការចូលរួមរបស់គ្រួសារកសិករជាកត្តាសំខាន់នាំទៅរកភាពជោគជ័យ។ គម្រោងបានគាំទ្រដល់ការរៀបចំបង្កើតផែនការសកម្មភាពនៅតាមបណ្តារាជធានី-ខេត្តគោលដៅទាំង១៣ ដោយរួមបញ្ចូលសកម្មភាពសំខាន់ៗរួមមាន ការផ្តល់សម្ភារផ្ទះសំណាញ់ ជំនួយបច្ចេកទេសរៀបចំដី រងបន្លែ ប្រព័ន្ធស្រោចស្រព ការបណ្តុះកូនបន្លែ ការប្រើជីធម្មជាតិ សម្របសម្រួលកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសដាំដុះ និងយល់ដឹងបន្ថែមពីអត្ថប្រយោជន៍នៃការដាំបន្លែក្នុងផ្ទះសំណាញ់ និងសកម្មភាពតាមដានការងារអនុវត្តរបស់កសិករ។

ជាលទ្ធផល ប្រជាជនចំនួន៣,៦០០គ្រួសារ មកពីរាជធានី-ខេត្តក្រុងទាំង១៣ ទទួលបានអត្ថប្រយោជន៍ពីគម្រោងដូចជា ផ្ទះសំណាញ់ដែលបានដំឡើងរួចចំនួន២៤០ខ្នង ដោយផ្ទះសំណាញ់១ខ្នងសម្រាប់កសិករ១៥គ្រួសារ។ ក្រៅពីផ្ទះសំណាញ់ គម្រោងបានផ្តល់ពូជកូនបន្លែចំនួន៤០០ដើម សម្រាប់ផ្ទះសំណាញ់១ខ្នង ស្មើនឹង៩,៦០០០កូន ប្រហាក់ប្រហែល៣៦,០០០ គីឡូនៃចំនួនសរុប។ គ្រួសារចំនួន៣,៦៩៦គ្រួសារ ទទួលបានកូនបន្លែចំនួន១,៤៧៨,៤០០ សំណាញ់មុងចំនួន៣៦,៩៦០ គីឡូ និងជី៥៥,៤៤ ០០ គីឡូ។

ក្រៅពីនេះ គម្រោងបានសម្របសម្រួលជំនួយបច្ចេកទេស និងការតាមដានក្នុងដំណាក់កាលអនុវត្តដើម្បីឱ្យកសិករអាចផលិតបន្លែមានសុវត្ថិភាព និងគុណភាពខ្ពស់។ កសិករបានសិក្សាពីរបៀបរៀបចំដី រងបន្លែ រៀបចំផែនការដាំកូនបន្លែ ការប្រើជីធម្មជាតិ និងរៀបចំប្រព័ន្ធស្រោចស្រពខ្នាតតូច និងជំនួយបច្ចេកទេស ការតាមដាន ដើម្បីឱ្យកសិករអាចកែប្រែរបៀបដាំបានល្អជាងមុន។

ផ្ទះសំណាញ់ **២៤០** បានដំឡើងរួច






ជីធម្មជាតិ **៣៦,០០០** គ.ក បានចែកចាយដល់ដៃអ្នកទទួលផល

វគ្គបណ្តុះបណ្តាល **១៣** ដង

គ្រួសារ **៣,៦៩៦** ទទួលបានផ្ទះសំណាញ់

ចំណីមាន់ **៩៦,០០០** គ.ក ចែកជូនអ្នកទទួលផល



# ភាពជោគជ័យរបស់ អ្នកទទួលផលគម្រោង

ការចិញ្ចឹមមាន់ជាប្រភពចំណូលបន្ថែម ដើម្បីលើកកម្ពស់ជីវភាពរបស់សហគមន៍ក្នុងពេលមានការរីករាលដាលនៃជំងឺកូវីដ១៩

# កសិករចិញ្ចឹមមាន់

## *ការចិញ្ចឹមមាន់បានផ្តល់ប្រាក់ចំណូលដល់សហគមន៍ ក្នុងកំឡុងពេលមានការរីករាលដាលនៃជំងឺកូវីដ១៩*

ការចិញ្ចឹមមាន់បានផ្តល់ប្រាក់ចំណូលដល់សហគមន៍ ក្នុងកំឡុងពេលមានការរីករាលដាលនៃជំងឺកូវីដ១៩។ អ្នកស្រី **ឈឹម សាមឿន** រស់នៅជាប់មាត់ទន្លេមេគង្គ ក្នុងភូមិសោប ឃុំសោប ស្រុកព្រែកប្រសព ខេត្តក្រចេះ។ អ្នកស្រីរស់នៅជាមួយប្តី និងកូនប្រាំមួយនាក់ ដោយរកប្រាក់ចំណូលបន្ថែមពីការចិញ្ចឹមមាន់ក្នុងរយៈពេលខ្លី និងប្រើប្រាស់ថវិកាបន្តិចបន្តួចលើការថែទាំ និងវ៉ាក់សាំង។ CERC បានផ្តល់ជម្រើសវិធីសមញ្ញៗដល់អ្នកស្រីដើម្បីចិញ្ចឹមមាន់ ដែលជាប្រភពប្រាក់ចំណូលសម្រាប់គ្រួសារជំនួសឱ្យការពឹងផ្អែកតែទៅលើមុខរបរស៊ីឈ្នួលប្រចាំថ្ងៃក្នុងវិស័យសំណង់។



*“អ្នកស្រី **ឈឹម សាមឿន** បានឱ្យដឹងថា កូវីដ១៩ បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គ្រួសារខ្ញុំនិងកូនប្រុសរបស់ខ្ញុំបាត់បង់ការងារធ្វើអំឡុងពេលមានការរីករាលនៃជំងឺកូវីដ១៩ ហើយខ្ញុំត្រូវប្រឹងប្រែងធ្វើការបន្ថែមដើម្បីរកប្រាក់ចិញ្ចឹមកូនៗរបស់ខ្ញុំ។ ដំបូងឡើយ ខ្ញុំមានការបារម្ភខ្លះៗដែរលើការចិញ្ចឹមមាន់ ហើយពេលខ្លះខ្ញុំបានបាត់បង់មាន់ទាំងនោះដោយសារបញ្ហាការប្រែប្រួលអាកាសធាតុ ឬជំងឺផ្សេងៗ។”*

អ្នកស្រី **ឈឹម សាមឿន** កសិករចិញ្ចឹមមាន់ កំពុងឱ្យចំណីមាន់ និងរូបភាពកំឡុងពេលជួបសម្ភាសន៍ជាមួយក្រុមការងាររបស់គម្រោង CASDP ។
រូបភាព ៖ លោក អ៊ែល ជួន ឆ្នាំ២០២២

CERC បានដើរតួនាទីជួរមុខឆ្លើយតបទៅនឹងជំងឺកូវីដ១៩ នៅជនបទ។ ជំងឺកូវីដ១៩ បានធ្វើឱ្យវិស័យកសិកម្មទទួលរងផលប៉ះពាល់ខ្លាំង និងបានគំរាមកំហែងដល់សន្តិសុខស្បៀងជារួម។ ក្រោមហិរញ្ញប្បទានរបស់ធនាគារពិភពលោក CERC បានរួមចំណែកដោះស្រាយផលប៉ះពាល់អវិជ្ជមានលើគ្រួសារងាយរងគ្រោះនៅជនបទ។



**ប្តីអ្នកស្រី ឈឹម សាមឿន** កំពុងថ្លឹងមាន់ និងរូបភាពកំឡុងពេលជួបសម្ភាសន៍ជាមួយក្រុមការងាររបស់គម្រោង CASDP ។
រូបភាព៖លោក អ៊ែល ជួន ឆ្នាំ២០២២

*"អ្នកស្រីបានបន្តថា CERC បានផ្តល់ក្តីសង្ឃឹមច្រើនដល់គ្រួសាររបស់ខ្ញុំ តាមរយៈការផ្តល់ពូជមាន់ និងសម្ភារផ្សេងទៀត។ ធាតុចូលកសិកម្មដែលគម្រោងបានផ្តល់ឱ្យរួមមាន ពូជមាន់៧ក្បាលក្នុងមួយគ្រួសារ ទ្រុងមាន់ ចូដាក់ចំណីសត្វ ចំណី វ៉ាក់សាំង និងថ្នាំសម្រាប់មាន់។ ដោយមានការជួយជ្រោមជ្រែងពី CERC ឥឡូវនេះប្តីរបស់ខ្ញុំអាចធ្វើការនៅផ្ទះបាន មានពេលចិញ្ចឹមមាន់ដោយប្រើបច្ចេកទេសផលិតចំណីមាន់ដែលគាត់បានរៀនសូត្រពីគម្រោង។ បច្ចុប្បន្ន មាន់របស់ខ្ញុំលូតលាស់លឿនណាស់ ព្រោះប្តីខ្ញុំយល់ពីរបៀបផលិត និងឱ្យចំណីមាន់ដោយប្រើបន្លែគ្រប់មុខ និងបាញ់ថ្នាំសម្លាប់សត្វល្អិត ដើម្បីសម្អាតទ្រុងចិញ្ចឹម។ ជាលទ្ធផល ឥឡូវខ្ញុំមានលុយខ្លះចិញ្ចឹមគ្រួសារ ដែលបានមកពីការលក់មាន់យកសាច់។"*

CERC បានចាប់ផ្តើមអនុវត្តនៅក្នុងខែកញ្ញា ឆ្នាំ២០២០ ហើយកម្មវិធីចិញ្ចឹមមាន់ដែលបានដាក់ឱ្យដំណើរការ បានជួយលើកកម្ពស់កម្រិតជីវភាពកសិករបានប្រសើរជាងមុន ។ ជាក់ស្តែង អ្នកស្រី **ឈឹម សាមឿន** អាចរកប្រាក់ចំណូលបាន៥០% សម្រាប់គ្រួសារ បានមកពីការចិញ្ចឹមមាន់យកសាច់ ។ គាត់មានមាន់៧០ ក្បាល ហើយអាចលក់បានយ៉ាងហោចណាស់១៥គីឡូក្នុងមួយខែ ជួនកាលលើសពី២០គីឡូ ក្នុងមួយខែអាស្រ័យលើពេលមានកម្មវិធីបុណ្យ ឬពិធីមង្គលការ ។ អ្នកស្រីអាចលក់បានតម្លៃ១៥,០០០រៀលក្នុង១គីឡូ ( ស្មើ៤ដុល្លារ ) និងប្រាក់ចំណេញសុទ្ធចន្លោះពី ២២៥០០០ ទៅ ៣០០,០០០ រៀល ( ស្មើ៧៥ដុល្លារ ) រៀងរាល់បីខែម្តង បន្ទាប់ពីទូទាត់លើការចំណាយផ្សេងៗរួមមាន វ៉ាក់សាំង និងថ្នាំកម្ចាត់មេរោគជាដើម ។

*"ខ្ញុំ និងស្វាមីបានប្តេជ្ញាចិត្តចិញ្ចឹមមាន់ និងជួយធ្វើការងាររគ្នា ដើម្បីឱ្យមាន់របស់យើងលូតលាស់បានលឿន។ យើងសង្ឃឹមថាអាចលក់មាន់បានចន្លោះពី១០ទៅ១៥ ក្បាលក្នុងមួយវគ្គប្រមូលផលក្នុងចំណោម៧០ក្បាល។ ចំណែកនៅរដូវមង្គលការវិញ យើងអាចលក់បាន១៧០០០ រៀលក្នុងមួយគីឡូ។ ទៅថ្ងៃអនាគត ខ្ញុំចង់បង្កើនចំនួនមាន់បន្ថែមទៀតដើម្បីរកចំណូល។ មុនពេលចិញ្ចឹមមាន់ ខ្ញុំមិនមានថវិកាច្រើនទេ តែឥឡូវខ្ញុំមានថវិកាសម្រាប់ប្រើប្រាស់លើម្ហូបអាហារ និងការថែទាំសុខភាព។ ឥឡូវនេះខ្ញុំលែងពិបាកចាយវ៉ាយទៀតហើយ ហើយខ្ញុំអាចកាត់បន្ថយការពឹងផ្អែកមួយកម្រិតលើការស៊ីឈ្នួលរកកម្រៃប្រចាំថ្ងៃ។ បើទោះបីជាគ្មានការងាររកប្រាក់ចំណូលប្រចាំថ្ងៃក្តីក៏ខ្ញុំនៅតែមានថវិកាផ្ទាល់ខ្លួនសម្រាប់ចាយដែរ។"*



រូបភាពដំឡើងទ្រុងមាន់ ចែកកូនមាន់ និងឈ្មួញប្រមូលទិញមាន់ពីកសិករ ដែលជាអ្នកទទួលផលពីសមាសភាគ CERC ។
រូបភាព៖លោក អ៊ែល ជួន ឆ្នាំ២០២២

ក្រៅពីលក់មាន់យកសាច់ អ្នកស្រី **ឈឹម សាមឿន** ក៏បានចែកចាយលក់ពូជកូនមាន់ និងចំណីឱ្យអ្នកជិតខាងក្នុងភូមិជាមួយគ្នា ។ បច្ចុប្បន្ន អ្នកស្រីបានចេះស្ទាត់ពីរបៀបលាយចំណីមាន់ ហើយបានចែករំលែកបទពិសោធន៍ និងបច្ចេកទេសជាមួយអ្នកភូមិដូចគ្នា ។ មិនយូរប៉ុន្មាន អ្នកភូមិចាប់ផ្តើមស្នើសុំចែកទិញចំណី និងពូជមាន់ពីអ្នកស្រីយកទៅចិញ្ចឹមបន្ត ។

ក្នុងពេលអនុវត្តសកម្មភាព CERC បានសម្របសម្រួលវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានបច្ចេកទេសចិញ្ចឹមមាន់ និងមាន់យកស៊ុត ។ កសិករត្រូវបានជ្រើសរើសសម្រាប់កម្មវិធីបណ្តុះបណ្តាលចិញ្ចឹមមាន់ក្នុងទ្រុងដែលមានទំហំ ២.៥ម គុណ ៤ម មានជញ្ជាំងបិទជិតជាប់គ្នា ។ ចំណេះដឹងពីរបៀបផ្តល់ចំណីឱ្យបានត្រឹមត្រូវ ផ្តល់វ៉ាក់សាំង និងថ្នាំការពារ ក៏ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលនោះដែរ ។ កសិករដែលផលិតកូនមាន់សម្រាប់លក់ត្រូវបានផ្តល់កន្លែងភ្ញាស់កូនមាន់ត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។



*“ការចិញ្ចឹមមាន់មានភាពងាយស្រួល ហើយជាការងារស្រាលៗ ។ នៅពេលព្រឹកឡើង អ្នកស្រីសម្អាតទ្រុង រៀបចំចំណី និងដាក់ទឹកឱ្យមាន់ នេះជាការងារតាមទម្លាប់ ។ ទោះបីប្តីរបស់អ្នកស្រីអត់មានការងារធ្វើ ក៏អ្នកស្រីនៅតែមានលុយចិញ្ចឹមគ្រួសារដែរ នេះជាអត្ថប្រយោជន៍ដែលអ្នកស្រីទទួលបានពីគម្រោង ។”*

អ្នកស្រី **ឈឹម សាមឿន** កសិករចិញ្ចឹមមាន់ ថ្លែងអំណរគុណដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងកំឡុងពេលជួបសម្ភាសន៍ជាមួយតំណាងគម្រោង CASDP ។ រូបភាព៖លោក អ៊ែល ជួន ឆ្នាំ២០២២

ការចិញ្ចឹមមាន់បានផ្លាស់ប្តូរជីវភាពរស់នៅទាំងស្រុងសម្រាប់កសិករភាគច្រើន ក្រៅពីបំពេញតម្រូវការម្ហូបអាហារ ឥឡូវនេះគ្រួសារពួកគេក៏មានប្រាក់សន្សំសម្រាប់គ្រួសារ ។ ការផ្លាស់ប្តូរនេះបានជំរុញអ្នកភូមិផ្សេងទៀតងាកមកចាប់ផ្តើមចិញ្ចឹមមាន់ជាបណ្តើៗ ។ ជាក់ស្តែង អ្នកស្រី **ឈឹម សាមឿន** អាយុ៤៨ ឆ្នាំ ជាកសិកររស់នៅភូមិសោប ឃុំសោប ធ្លាប់ប្រកបរបរធ្វើស្រែចម្ការ ដែលរកប្រាក់កម្រៃស្មើរតែមិនគ្រប់សម្រាប់អាហារប្រចាំថ្ងៃ ។ ប៉ុន្តែសព្វថ្ងៃនេះ ដោយសារការគាំទ្ររបស់គម្រោង CERC អ្នកស្រីអាចផ្គត់ផ្គង់គ្រួសារបានគ្រប់គ្រាន់តាមរយៈការការចិញ្ចឹមមាន់ និងភ្ញាស់កូនមាន់ ។



# កសិករចិញ្ចឹមត្រី

*ការបង្កើនលទ្ធភាពទទួលបានជាតុចូលវារីវប្បកម្មសម្រាប់កសិករងាយរងគ្រោះដើម្បីជានាប្រាក់ចំណូលគ្រួសារប្រកបដោយនិរន្តរភាព៖ វិធីដែល លោក **លឹម ធឿន** និងលោក **ឃុន លី** អាចតស៊ូទប់ទល់ទៅនឹងវិបត្តិកូវីដ-១៩*

# កសិករចិញ្ចឹមត្រី

## *ការបង្កើនលទ្ធភាពទទួលបានធាតុចូលវារីវប្បកម្មសម្រាប់កសិករងាយរងគ្រោះដើម្បីធានាប្រាក់ចំណូលគ្រួសារប្រកបដោយនិរន្តរភាព៖ វិធីដែលលោក យុន លី អាចតស៊ូទប់ទល់ទៅនឹងវិបត្តិកូវីដ-១៩*

លោក **យុន លី** រស់នៅភូមិពង្រ ឃុំនាងទើត ស្រុកតំបែរ ខេត្តត្បូងឃ្មុំ ជាកសិករចិញ្ចឹមត្រី។ តាំងពីមានការរីករាលដាលនៃជំងឺកូវីដ១៩ លោកមិនបានចេញទៅធ្វើការនៅខាងក្រៅដូចសព្វមួយដងទេ លោកនៅតែផ្ទះ។ CERC សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តត្បូងឃ្មុំ បានចុះចែកកូនត្រី សម្ភារកសិកម្ម និងសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមត្រីអណ្តែង ដើម្បីឱ្យវាហុចផលបានល្អ និងជួយឱ្យគាត់អាចមើលថែគ្រួសារ និងចិញ្ចឹមត្រីនៅផ្ទះបាន។

ចំណែកធាតុចូលកសិកម្មដែលគម្រោងបានផ្តល់ជូន រួមមាន ចំណីត្រី ត្រី និងអាហារបំប៉នសុខភាព ដោយគ្រួសារនីមួយៗទទួលបានចំណីត្រីចំនួនប្រាំបីកញ្ចប់សម្រាប់ប្រើបាន២រដូវតាមលក្ខណៈបច្ចេកទេស អាហារបំប៉នសុខភាពចំនួន៣ប្រអប់ និងការបែងចែកកូនត្រីចំនួន១,០០០ ក្បាលក្នុងមួយគ្រួសារ។

ចំពោះបច្ចេកទេសចិញ្ចឹមត្រីវិញ គម្រោងបានណែនាំពីរបៀបសង់អាងចិញ្ចឹមត្រីមានទំហំ( ៥ម គុណ ៤ម ) ប្រព័ន្ធប្រឡាយ ឬស្រះទឹកនៅតាមផ្ទះ របៀបថែទាំត្រីអណ្តែង ការបង្ហូរទឹកកខ្វក់ និងការបន្ថែមទឹកសាបទៅក្នុងអាងទឹកប្លាស្ទិក មូលដ្ឋានគ្រឹះនៃការធ្វើរោគវិនិច្ឆ័យ និងការការពារជំងឺត្រី ដែលកសិករអាចរៀនសូត្រ និងយកទៅអនុវត្តបន្តក្រោយពេលគម្រោងបានបញ្ចប់។ លោក **យុន លី** បានឲ្យដឹងថា៖



លោក **យុន លី** កសិករចិញ្ចឹមត្រី កំពុងឱ្យចំណីមាន់ និងរូបភាពកំឡុងពេលជួបសម្ភាសន៍ជាមួយក្រុមការងាររបស់គម្រោង CASDP ។
រូបភាព៖លោក នាង សុទ្ធនា ឆ្នាំ២០២២

*“ ដើម្បីរក្សាគុណភាពទឹកនៅក្នុងអាងចិញ្ចឹមត្រី យើងត្រូវបិទបាំងកុំឲ្យមានធូលី ដែលបង្កបានជាក្លិនមិនល្អសម្រាប់ទឹកក្នុងអាង។ យើងនឹកស្រម៉ៃថា មនុស្ស និងសត្វមិនខុសគ្នាទេ បើមានក្លិនអាក្រក់ យើងពិតជាពិបាករស់នៅណាស់។ ក្រៅពីនេះ គ្រូឧទ្ទេសនាមក៏បានមកតាមដាន និងពន្យល់ថា ពេលត្រីឈឺ ដោយត្រូវបន្ថែមអំបិលទៅក្នុងទឹក ហើយកូរឱ្យសព្វ រួចប្រោះវាចូលក្នុងធុងត្រី ដើម្បីកុំឱ្យត្រីឈឺ។ លោក **យុន លី** បានចែករំលែកចំណេះដឹងពីវិធីចិញ្ចឹមត្រីតាមពីររបៀបផ្សេងគ្នាគឺការចិញ្ចឹមត្រីនៅក្នុងស្រះចំហ ឬក្រោមតង់។ ការចិញ្ចឹមត្រីដោយប្រើប្រព័ន្ធតង់មានភាពងាយស្រួលក្នុងការថែទាំ និងផ្តល់លទ្ធផលល្អប្រសើរ។ ”*

លោក **ឃុន លី** បានចែករំលែកចំណេះដឹងពីវិធីចិញ្ចឹមត្រីតាមពីររបៀបផ្សេងគ្នាគឺការចិញ្ចឹមត្រីនៅក្នុងស្រះចំហ ឬក្រោមតង់។ ការចិញ្ចឹមត្រីដោយប្រើប្រព័ន្ធតង់មានភាពងាយស្រួលក្នុងការថែទាំ និងផ្តល់លទ្ធផលល្អប្រសើរ។

ការប្រឈមផ្នែកជំងឺរាតត្បាតកូវីដ១៩ មិនបានបង្អាក់ដំណើការអនុវត្ត CERC ទេ។ ជាក់ស្តែងជិតមួយឆ្នាំកន្លងមកនេះ កសិករចិញ្ចឹមត្រីប្រហែល៤០០ នាក់បានទទួលចំណេះដឹងស្តីពីបច្ចេកទេសចិញ្ចឹមត្រីឬកង្កែប ដែលអាចឱ្យគ្រួសារទាំងនេះបង្កើនប្រាក់ចំណូលគ្រួសារបាន។ លោក **ឃុន លី** អាចប្រមូលផលបានប្រហែល៥ ទៅ៦មួយក្បាលក្នុងមួយគីឡូ។ ចំណែកតម្លៃវិញគាត់អាចលក់បានពី១០០០០ ទៅ១១០០ រៀលក្នុង១គីឡូ និងប្រហែល១០០គីឡូនៅជុំទី១។ លោក **លី** សប្បាយចិត្តចំពោះអត្ថប្រយោជន៍ពីការចិញ្ចឹមត្រី ព្រោះវាបានផ្តល់អាហាររូបបត្ថម្ភគ្រប់គ្រាន់សម្រាប់គ្រួសារ និងមានពេលធ្វើការនៅផ្ទះដែលអាចការពារខ្លួនជៀសផុតពីជំងឺកូវីដ១៩។

លោក **លី** បានឱ្យដឹងថាគាត់អាចរកចំណូលបានពីការចិញ្ចឹមត្រីប្រហែល៥ម៉ឺនរៀល លក់ឲ្យអ្នកជិតខាងដែលបានទិញ១គីឡូ ឬ២គីឡូ។ យើងចំណាយពេលតែពីរបីខែ ប៉ុណ្ណោះ យើងអាចប្រមូលផលបានហើយ ម៉្យាងវិញទៀតយើងមិនបារម្ភពីទីផ្សារលក់ត្រីទេ។ បច្ចុប្បន្នគ្រួសារ លោក **ឃុន លី** ហាក់មានជីវភាពធូធារជាងមុន ក្រោយពីគាត់បានចូលរួមជាមួយ CERC។ លោកបានប្តេជ្ញាបន្តចិញ្ចឹមត្រី ដើម្បីរកប្រាក់ចំណូលគ្រួសារតទៅថ្ងៃអនាគត។

លោក **ឃុន លី** បន្តថា ក្រោយពេលប្រមូលផលរួច ខ្ញុំមានគម្រោងទិញកូនត្រីមកចិញ្ចឹមម្តងទៀត ព្រោះសម្ភារៈដែលផ្តល់ដោយគម្រោងអាចប្រើប្រាស់បានពីរដង ជាពិសេសតង់របស់ខ្ញុំនៅតែអាចប្រើប្រាស់បាន។ គ្រូបង្គាត់ពន្យល់ថា តង់ដែលបំពាក់រួចអាចប្រើបានបីឆ្នាំ។ លោក **ឃុន លី** បានដាក់ក្តីសង្ឃឹមលើការចិញ្ចឹមត្រីបន្ទាប់ពីគាត់ទទួលបានជោគជ័យ ហើយមានបំណងចែករំលែកចំណេះដល់សហគមន៍ឱ្យចេះចិញ្ចឹមត្រីដូចគាត់ដែរ ដើម្បីពួកគេមានប្រាក់ ចំណូលចិញ្ចឹមគ្រួសារ។



លោក **ឃុន លី** កសិករចិញ្ចឹមត្រី កំពុងរាប់លុយដែលបានមកពីលក់ត្រី និងរូបភាពកំឡុងពេលជួបសម្ភាសន៍ជាមួយក្រុមការងាររបស់គម្រោង CASDP ។
រូបភាព៖លោក នាង សុទ្ធនា ឆ្នាំ២០២២

*“ខ្ញុំមានចំណាប់អារម្មណ៍លើការចិញ្ចឹមត្រី ក្រោយពេលខ្ញុំបានមើលកម្មវិធីវារីវប្បកម្មតាមទូរទស្សន៍ពីមុនមកដែរ។ នៅថ្ងៃអនាគត ខ្ញុំនឹងចិញ្ចឹមត្រីពេលខ្ញុំចាស់មិនអាចទៅណាបាន។ ខ្ញុំនឹងមានពេលចិញ្ចឹមត្រីនៅផ្ទះ និងបានមើលថៃគ្រួសារផងដែរ។ ទាក់ទងនឹងការចិញ្ចឹមត្រីនេះដែរ ខ្ញុំសូមផ្តាំផ្ញើដល់អ្នកជិតខាងដែលចាប់អារម្មណ៍ឱ្យពិចារណាចិញ្ចឹមត្រី ព្រោះវាបានផ្តល់ប្រយោជន៍ច្រើនឱ្យយើង។ ដោយសារការគាំទ្ររបស់គម្រោងទើបខ្ញុំមានជីវភាពធូរធារគ្រាន់បើដូចសព្វថ្ងៃ ហើយខ្ញុំសូមថ្លែងអំណរគុណដល់ CERC ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងធនាគារពិភពលោក ដែលបានយកចិត្តទុកដាក់ចែកពូជត្រីឱ្យខ្ញុំ។ ខ្ញុំសូមជូនពរថ្នាក់ដឹកនាំទាំងអស់នៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងធនាគារពិភពលោកមានសុភមង្គល និងចម្រុងចម្រើន។”*



# កសិកម្មចិញ្ចឹមកង្កែប

ការបង្កើនលទ្ធភាពទទួលបានធាតុចូលវារីវប្បកម្មសម្រាប់កសិករងាយរងគ្រោះ
ដើម្បីធានាប្រាក់ចំណូលគ្រួសារប្រកបដោយនិរន្តរភាព៖ វិធីដែល
លោក **លឹម ធឿន** អាចតស៊ូទប់ទល់ទៅនឹងវិបត្តិកូវីដ-១៩

# កសិករចិញ្ចឹមកង្កែប

CERC សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្តត្បូងឃ្មុំ បានចែកចាយពូជកង្កែបដល់កសិករគោលដៅសម្រាប់ចិញ្ចឹមនៅតាមផ្ទះដើម្បីរកប្រាក់ចំណូលសម្រាប់គ្រួសារ។ CERC បានផ្តល់ធាតុចូលកសិកម្ម និងសម្របសម្រួលវគ្គបណ្តុះបណ្តាលដល់កសិករស្តីពីរបៀបចិញ្ចឹមកង្កែប ដូចជាការជ្រើសរើសទីតាំងធ្វើអាង ឬស្រះចិញ្ចឹមកង្កែប ការដំឡើងស្រទាប់ផ្លាស្ទិក ការព្រលែងកូនកង្កែប ការចិញ្ចឹមកង្កែប និងរបៀបប្រមូលផលកង្កែប។

លោក **លឹម ធឿន** រស់នៅភូមិគរ ឃុំនាងតឿ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ ត្រូវបានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត និងអាជ្ញាធរមូលដ្ឋានបានជ្រើសរើសឱ្យចូលរួមវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមកង្កែប និងទទួលសម្ភារៈកសិកម្ម ដូចជា តង់ចិញ្ចឹមកង្កែប អាហារបំប៉នសម្រាប់កង្កែប៣កញ្ចប់។ លោក លឹម ធឿន បានឱ្យដឹងថា៖ ពេលកូនកង្កែបដឹកមកដល់ផ្ទះ គេត្រូវទុកវាក្នុងទ្រុងរយៈពេល៣ទៅ៤ម៉ោង មុននឹងយកវាទៅដាក់ក្នុងអាងចិញ្ចឹម បន្ថែមទឹក ហើយការពារកុំឱ្យជ្រាបទឹក។ រាល់ពេលដែលបន្ថែមទឹក ត្រូវបាញ់លើកង្កែបថ្នមៗ ដើម្បីឱ្យដំណក់ទឹកអាចលាងសម្អាតស្បែកកង្កែបបានល្អ។ លោក **លឹម ធឿន** បានបន្តទៀតថា ចំពោះបច្ចេកទេសចិញ្ចឹមកង្កែបវិញគេប្រើសំបកកង់រថយន្តចាស់ ឬសំបកកង់ម៉ូតូសម្រាប់ធ្វើជាជម្រក។ ចំណែកឯការថែទាំវិញ លោក **លឹម ធឿន** បានឱ្យដឹងថា៖






តំណាងក្រុមហ៊ុន **អប្សរា** កំពុងចែកធាតុចូលកសិកម្ម និងរូបភាពកំឡុងពេលជួបសម្ភាសន៍ជាមួយក្រុមការងាររបស់គម្រោង CASDP ។
រូបភាព៖លោក នាង សុទ្ធនា ឆ្នាំ២០២២



*“ចំពោះការថែទាំវាមិនពិបាកទេ យើងមើលថា តើវាឃ្លានចំណី ឬអត់ ហើយយើងត្រូវលាយជី៣ស្លាបព្រាបាយ អោយសព្វល្អ រួចទុកចោល១០នាទី ទើបប្រោះៗវាទៅក្នុងស្រះតែម្តងៗ យើងដាក់ចំណីតិចតួចបានហើយប្រចាំថ្ងៃ វាអាស្រ័យលើអ្វីដែលយើងសង្កេត យើងផ្តល់អាហារនៅពេលដែលកង្កែបត្រូវការចំណី។”*

លោក **លឹម ធឿន** កំពុងសំអាតអាងចិញ្ចឹមកង្កែប និងរូបភាពកំឡុងពេលជួបសម្ភាសន៍ជាមួយក្រុមការងាររបស់គម្រោង CASDP ។ រូបភាព៖លោក នាង សុទ្ធនា ឆ្នាំ២០២២

លោក លឹម ធឿន បានបង្ហាញពីចំណាប់អារម្មណ៍របស់លោកក្នុងការចិញ្ចឹមកង្កែប ។ លោកថា កង្កែបមានទីផ្សារល្អ គាត់អាចលក់កង្កែបឲ្យអ្នកជិតខាងបានបន្ទាប់ពីផ្គត់ផ្គង់តម្រូវការគ្រួសារគាត់ ។  លោកប្តេជ្ញាថានឹងបន្តចិញ្ចឹមកង្កែបក្នុងដំណាក់កាលបន្ទាប់ ហើយគ្រោងពង្រីកការចិញ្ចឹមទ្រង់ទ្រាយធំ និងលក់បានច្រើនជាងមុន ។

*“ការចិញ្ចឹមកង្កែបមានសារៈសំខាន់ណាស់ ព្រោះយើងមិនចាំបាច់ចំណាយលុយទិញអាហារបន្ថែមសម្រាប់គ្រួសារមកពីខាងក្រៅ និងម៉្យាងវិញទៀតខ្ញុំអាចសន្សំប្រាក់ខ្លះដើម្បីចិញ្ចឹមជីវិត។ បច្ចុប្បន្នខ្ញុំរៀនសូត្របានច្រើនពីរបៀបចិញ្ចឹម និងថែទាំកង្កែប។ ខ្ញុំរំភើបចិត្តណាស់ ហើយខ្ញុំមានគម្រោងពង្រីកទ្រុងឲ្យកាន់តែធំជាងនេះនៅឆ្នាំក្រោយៗទៀត។ ជាចុងក្រោយខ្ញុំសូមថ្លែងអំណរគុណដល់ CERC ក្រោមគម្រោងពិពិធកម្មកសិកម្មកម្ពុជា តាមរយៈមន្ទីរកសិកម្ម និងសូមជូនពរឱ្យទទួលបានជោគជ័យគ្រប់ភារកិច្ច។”*



លោក **លឹម ធឿន** រូបភាពកំឡុងពេលជួបសម្ភាសន៍ជាមួយក្រុមការងារគម្រោង CASDP ។ រូបភាព៖លោក នាង សុទ្ធនា ឆ្នាំ២០២២



# កសិករដាំបន្លែសុវត្ថិភាព នៅក្នុងផ្ទះសំណាញ់

ស្ត្រីនៅភូមិចំបក់ទទួលបានបន្លែមានសុវត្ថភាព និងរបបអាហារូបត្ថម្ភបាន
ប្រសើរជាងមុនក្នុងពេលមានការរីករាលដាលនៃជំងឺកូវីដ១៩

# កសិករដាំបន្លែសុវត្ថិភាព

## *ស្ត្រីនៅភូមិចំបក់ទទួលបានបន្លែមានសុវត្ថភាព និងរបបអាហាររូបត្ថម្ភបានប្រសើរជាងមុនក្នុងពេលមានការរីករាលដាលនៃជំងឺកូវីដ-១៩*

អ្នកស្រី **ផូ ចាន់សុថល** ជាស្ត្រីមេម៉ាយរស់ជាមួយឪពុកម្តាយចាស់ និងកូនអាយុ៩ឆ្នាំ នៅភូមិចំបក់តូច ឃុំកាត់ភ្លុក ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ បានរងផលប៉ះពាល់ដោយសារការរីករាលដាលនៃ ជំងឺកូវីដ១៩។ ក្រោមជំនួយឧបត្ថម្ភពី CERC អ្នកស្រីបានដាំបន្លែសុវត្ថិភាពនៅក្នុងផ្ទះសំណាញ់ ក្នុងដីឡូត៍របស់អ្នកស្រី។ អ្នកស្រីទទួលបានការបណ្តុះបណ្តាលបច្ចេកទេសដាំ និងថែទាំបន្លែសុវត្ថិភាព ការប្រើប្រាស់ដី អាហាររូបត្ថម្ភ និងគុណប្រយោជន៍នៃការដាំបន្លែសុវត្ថិភាពក្នុងផ្ទះសំណាញ់។ អ្នកស្រី **ផូ ចាន់សុថល** អាចដាំបន្លែបានពីរដងក្នុងមួយរដូវកាល និងអ្នកស្រីទទួលបានការចាប់ អារម្មច្រើនពីប្រជាសហគមន៍ដូចគ្នាដែលមានបំណងចង់ដាំបន្លែសុវត្ថិភាពដូចអ្នកស្រីដែរ។ អ្នកស្រីបានឱ្យដឹងថា៖



អ្នកស្រី **ផូ ចាន់សុថល** កសិករដាំបន្លែសុវត្ថិភាពជួបសម្ភាសន៍ជាមួយក្រុមការងាររបស់គម្រោង CASDP ។
រូបភាព៖លោក នាង សុទ្ធនា ឆ្នាំ២០២២

> *“ចំពោះការដាំបន្លែសុវត្ថិភាពក្នុងផ្ទះសំណាញ់នេះ ខ្ញុំមិនបារម្ភពីការលក់ទេ។ ខ្ញុំអាចលក់បន្លែសុវត្ថិភាពឲ្យអាជីវករលក់ដុំបានចន្លោះពី៥០ ទៅ៦០គីឡូ ក្នុងមួយសប្តាហ៍ ហើយលក់បានតម្លៃ២៥០០រៀលក្នុងមួយគីឡូ។ ខ្ញុំអាចសន្សំបានប្រាក់ខ្លះសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារប្រចាំថ្ងៃមានដូចជា ថ្លៃទឹកភ្លើង និងថ្លៃសាលាកូនរៀន។ ប្រហែល៣០% នៃបន្លែដែលខ្ញុំទុកបរិភោគខ្លួនឯង ហើយសល់ប៉ុន្មានខ្ញុំអាចលក់នៅលើទីផ្សារបានផងដែរ។ ខ្ញុំអាចរកចំណូលបានជិតបីដងក្នុងមួយរដូវកាល។ បន្លែរបស់យើងមានរសជាតិខុសពីបន្លែដែលដាក់លក់នៅតាមទីផ្សារ វាមានរសជាតិឆ្ងាញ់ជាង។”*

CERC បានផ្ដល់សួនបន្លែបៃតងនៅក្នុងផ្ទះដល់កសិករ២០គ្រួសារ ដែលបានជ្រើសរើសចេញពីគ្រួសារមានបណ្ណក្រីក្រ(IDPoor) ហើយឥឡូវនេះពួកគេមានសួនបន្លែពណ៌បៃតងស្រស់ស្មើរពេញមួយឆ្នាំ។ នៅភូមិចំបក់ ស្រុកបរសេដ្ឋកាលដើមឡើយ រាល់ការស្រោចស្រពមានសម្រាប់តែការបង្កបង្កើនផលស្រូវប៉ុណ្ណោះ ដូច្នេះហើយគ្រួសារនីមួយៗមិនទទួលបានប្រព័ន្ធស្រោចស្រពសម្រាប់ចម្ការរបស់ពួកគេទេ។ CERC បានសម្របសម្រួលវគ្គបណ្ដុះបណ្ដាល និងផ្ដល់ប្រព័ន្ធស្រោចស្រពខ្នាតតូចដល់ អ្នកស្រី **ចាន់ សុថល** ដើម្បីបានប្រើប្រាស់នៅក្នុងផ្ទះគ្រប់រដូវកាល។

ដើម្បីបង្កើនសមត្ថភាពបន្ថែមលើការដាំបន្លែសុវត្ថិភាព គម្រោងបានផ្ដល់វគ្គបណ្ដុះបណ្ដាលរយៈមួយថ្ងៃមុនពេលផ្ដល់ធាតុចូលកសិកម្មដល់កសិករ។ វគ្គបណ្ដុះបណ្ដាលបានកំណត់ចំនួនអ្នកចូលរួមដោយគោរពតាមវិធានការបង្ការរបស់ក្រសួងសុខាភិបាលចំពោះការរក្សាគម្លាតសង្គម។ វគ្គបណ្ដុះបណ្ដាលនេះ បានបង្កលទ្ធភាពឱ្យអ្នកស្រីចេះច្នៃប្រឌិតក្នុងការដាំបន្លែសុវត្ថិភាពនៅក្នុងផ្ទះសំណាញ់ និងចែករំលែកចំណេះដឹងជាមួយអ្នកភូមិ និងសហគមន៍ដែលមានចំណាប់ចាប់អារម្មណ៍លើការដាំបន្លែសុវត្ថិភាព។

អ្នកស្រីបានឱ្យដឹងថា៖ ចំណេះដឹងដែលទទួលបានពី CERC ពិតជាមានសារៈសំខាន់ណាស់សម្រាប់ការដាំបន្លែរបស់ខ្ញុំ។ ខ្ញុំសូមអរគុណចំពោះគម្រោង ដែលផ្ដល់ឱកាសឱ្យខ្ញុំបានរៀនពីរបៀបរៀបចំដីឱ្យមានជីជាតិ ជីណាដែលត្រូវប្រើ និងអនុវត្ត និងជីសរីរាង្គណាដែលយើងអាចរៀបចំខ្លួនយើងបាន។



អ្នកស្រី **ផូ ចាន់សុថល** កសិករដាំបន្លែសុវត្ថិភាព កំពុងថែទាំបន្លែជាមួយម្ដាយរបស់អ្នកស្រីនៅក្នុងផ្ទះសំណាញ់ដែលទទួលបានពីគម្រោង CASDP។ រូបភាពជួបសម្ភាសន៍ជាមួយក្រុមការងាររបស់គម្រោង CASDP ។ រូបភាព៖លោក នាង សុទ្ធនា ឆ្នាំ២០២២

# បទពិសោធន៍ និងការអនុវត្តល្អរបស់ CERC

ការកែលម្អប្រព័ន្ធអាហារូបត្ថម្ភ និងការបង្កើនភាពធន់ទៅនឹងវិបត្តិនៃជំងឺកូវី១៩ ពិធជាមានសារៈសំខាន់សម្រាប់ប្រជាជនកម្ពុជា។ វិធានការនេះអាចសម្រេចបានលុះត្រាណាយើងត្រូវកសាងប្រព័ន្ធអាហាររូបត្ថម្ភដែលមានភាពប្រសើរជាងមុន និងមាននិរន្តរភាពរយៈពេលវែង។ CERC បានផ្តល់នូវភស្តុតាងសមស្របសម្រាប់កសិករអាចចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួនលើការចិញ្ចឹមត្រី មាន់ ឬខ្សែច្រវាក់តម្លៃផលិតកម្មកសិកម្មផ្សេងទៀត។

ការចិញ្ចឹមមាន់ និងត្រីខ្នាតតូចត្រូវបានអនុវត្តជាចម្បងដោយប្រជាជនក្រីក្រតាមជនបទ ដែលតែងបានជួបប្រទះនឹងអសន្តិសុខស្បៀងក្នុងរយៈពេលប៉ុន្មានឆ្នាំនៃការរាតត្បាតនៃជំងឺកូវីដ១៩។ តាមរយៈកិច្ចអន្តរាគមន៍របស់ CERC ម៉ូឌែលនៃការចិញ្ចឹមមាន់ និងត្រីលែងជាឧបសគ្គទៀតហើយសម្រាប់ប្រជាពលរដ្ឋនៅតាមជនបទ។ ម្យ៉ាងទៀតការចិញ្ចឹមមាន់ និងត្រីបានក្លាយប្រភពចំណូលសំខាន់ និងជាអាហារសំបូរដោយជីវជាតិសម្រាប់ពួកគេ ដែលធានាបានសន្តិសុខស្បៀង។ ផលិតកម្មចិញ្ចឹមមាន់ ត្រី ខ្នាតតូចមិនត្រឹមតែបានបង្កើនសារជាតុចិញ្ចឹមប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានរួមចំណែកយ៉ាងសំខាន់ដល់ការអនុវត្តកសិកម្មចម្រុះ និងការពង្រឹងភាពអង់អាចក្លាហានសម្រាប់ស្ត្រីនៅតាមជនបទផងដែរ។

ក្រៅពីអត្ថប្រយោជន៍នៃប្រព័ន្ធផលិតកម្មចិញ្ចឹមមាន់ខ្នាតតូច ជាទូទៅកសិករនៅតាមជនបទតែងត្រូវការជំនួយគាំទ្របន្ថែមដើម្បីឱ្យពួកគេទទួលបានអត្ថប្រយោជន៍ពេញលេញ ជៀសផុតពីហានិភ័យដែលកើតឡើងដោយសារជំងឺ និងការប្រែប្រួលអាកាសធាតុ។ បញ្ហាបែបនេះអាចដោះស្រាយបានជាមួយនឹងការគ្រប់គ្រងកសិកម្ម និងបសុសត្វកាន់តែប្រសើរ។

ជាក់ស្តែង ម៉ូឌែលនៃជំនួយបំពេញបន្ថែមទុនវិនិយោគ (matching grant ) ក្រោមគម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP) ត្រូវបានដាក់ឱ្យអនុវត្តសម្រាប់សហគមន៍កសិកម្ម ដែលត្រូវការទុនវិនិយោគបន្ថែមលើវិស័យកសិកម្ម ហើយពួកគេពិបាកស្វែងរកឥណទានកម្ចី។ ជាមួយគ្នានេះដែរ ជំនួយបំពេញបន្ថែមទុនវិនិយោគបានផ្តល់អត្ថប្រយោជន៍ដល់កសិករដែលពឹងផ្អែកខ្លាំងលើការធ្វើអាជីវកម្មតូចតាច ដែលមានបទពិសោធន៍អនុវត្តជាមួយ CERC ដើម្បីងាកទៅរកកសិធុរកិច្ចខ្នាតតូច។ និន្នាការនេះត្រូវបានចាត់ទុកថាជាម៉ូឌែលគំរូជោគជ័យមួយដែលបង្កើតឡើងដោយ CERC។ រហូតមកដល់ពេលនេះ ប្រជាពលរដ្ឋក្រីក្រដែលធ្លាប់បានទទួលការបណ្តុះបណ្តាលដោយជោគជ័យលើផ្នែកគ្រប់គ្រងការចិញ្ចឹមមាន់ និងចិញ្ចឹមត្រី ឬកង្កែប ក្នុងពេលមានការរីករាលនៃជំងឺកូវីដ១៩ ជាពិសេស ស្ត្រីដែលជាសមាជិកនៃសហគមន៍កសិកម្ម មានលទ្ធភាពទទួលបានហិរញ្ញប្បទាន ៤០% នៃទុនវិនិយោគបំពេញបន្ថែម ក្រោមគម្រោង CASDP យកទៅអភិវឌ្ឍន៍ផែនការពង្រីកអាជីវកម្មខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម។

CERC ២០២៣



# គម្រោងពិពិធកម្មកសិកម្មកម្ពុជា

www.casdp.maff.gov.kh
www.casdp.maff.gov.kh

THE WORLD BANK